ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែសីហា ឆ្នាំ២០២១

នៅក្នុងខែសីហា ឆ្នាំ២០២១នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

**១.១** សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន១លើក

ក-សកម្មភាពចូលរួមប្រជុំ

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយក្រុមការងាររៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ (ASEM13) តាមប្រព័ន្ធវីដេអូ។

ខ-សកម្មភាពចុះមូលដ្ឋាន

-នៅក្នុងសភាពការណ៍នៃការប្រយុទ្ធ និងទប់ស្កាត់នៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ដោយព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ និងការប្រឈមថ្មីដែលបណ្តាលមកពីមេរោគបំប្លែងខ្លួនប្រភេទដែលតា(Delta) សម្តេចប្រធានបានអញ្ជើញមកប្រចាំការ ដើម្បីដឹកនាំការងារជំនាញរៀងរាល់ថ្ងៃ និងដឹកនាំចាត់ចែងចូលរួមចំណែកដោះស្រាយជំនួយឧបត្ថម្ភ បន្ទាន់រួមមាន៖ អង្ករ ត្រីខកំប៉ុង ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកផ្លែឈើ ឱសថ ម៉ាស់ និងសម្ភារប្រើប្រាស់មួយចំនួនជូនមន្ត្រី កងកម្លាំង និងប្រជាពលរដ្ឋក្រីក្រ ដែលរងប៉ះពាល់ពីការបិទខ្ទប់នៅមូលដ្ឋានរាជធានីភ្នំពេញជាបន្តបន្ទាប់ ព្រមជាមួយនេះ សម្តេចប្រធានក៏បានណែនាំឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា ទីប្រឹក្សាថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យជួយដោះស្រាយនូវអំណោយចាំបាច់នានាទៅតាមលទ្ធភាព ដើម្បីចែកជូនប្រជាពលរដ្ឋងាយរងគ្រោះ និងប្រជាពលរដ្ឋក្រីក្រដែលកំពុងរស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងខេត្តមួយចំនួនទៀតផងដែរ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

គ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមដង្ហែ**ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងទៅកាន់ទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន

-បានអញ្ជើញជាអធិបតី និងផ្តល់ភ្លើងបូជាសពឯកឧត្តម **សុខ យាត** សមាជិកព្រឹទ្ធសភា នៅវត្តសុវណ្ណរង្សី សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។

ឃ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានចុះហត្ថលេខាលើព្រះរាជក្រមចំនួន៦ច្បាប់

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៩១ច្បាប់

-បានចុះហត្ថលេខាលើសំណើសុំព្រះរាជទានសិទ្ធិចំនួន៦ច្បាប់

-បានទទួលព្រះរាជសារប្រទានសិទ្ធិចំនួន៦ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៦ច្បាប់

-បានចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥ច្បាប់

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១១៥ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន១លើក។

ក-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមប្រជុំការងារចាំបាច់មួយចំនួនក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ចំនួន៣លើក

-បានអនុញ្ញាតឱ្យក្រុមការងារចូលជួបពិភាក្សា និងពិនិត្យការងារចាំបាច់មួយចំនួនចំនួន២លើក។

ខ-សកម្មភាពចុះមូលដ្ឋាន

-បានចាត់ឱ្យក្រុមការងារ នាំយករទេះសម្រាប់ជនពិការផ្តល់ជូនចាស់ជរាចំនួន ៣រូប ដែលមានជំងឺប្រចាំកាយ ស្ថិតនៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល និងនាំយកស្បៀងអាហារជូនដល់សមាគមតន្ត្រីសំនៀងជនពិការ ដែលកំពុងជួបការខ្វះខាតក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។

-បានអញ្ជើញចូលរួមក្នុងពិធីបូជាសពឯកឧត្តម **សុខ ឃាត** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភា និងជាសមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅវត្តសុវណ្ណរង្សី ស្ថិតក្នុងភូមិលេខ៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។

គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤២ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១ មុខងារនីតិកម្ម

-បានអញ្ជើញចូលរួមប្រជុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៣៖ **១**-សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ **២**-សេចក្តីព្រាងច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង**៣**-សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបូកបី ស្តីពីការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់ដោយមានការផ្សាយចេញពីវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ជាមួយនឹងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **វង្សី វិស្សុត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើគម្រោងថវិកាឆ្នាំ២០២២ របស់ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមប្រជុំ ដើម្បីឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំសេចក្តី

ព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ ផ្សាយចេញពីរដ្ឋសភា។

## ២.២ មុខងារតំណាង

-បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួង ស្តីពីវឌ្ឍនភាពនៃការងារពិនិត្យ សិក្សា និងចងក្រងឯកសារទីតាំងដី ដែលប្រជាជនបានប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែង ក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ នៅក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង

-បានអញ្ជើញចុះជួបក្រុមប្រឹក្សាស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដើម្បីសំណេះសំណាល ស្តីពីការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ និងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព

-បានអញ្ជើញចុះជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់កន្ទោក ដើម្បីឈ្វេងយល់អំពីស្ថានភាពទូទៅនៃជំងឺកូវីដ-១៩ ក្នុងមូលដ្ឋាន ការងារចាក់វ៉ាក់សាំង ដល់កុមារពីអាយុ១២ ដល់១៧ឆ្នាំ និងការចែកប័ណ្ណជូនបងប្អូនប្រជាពលរដ្ឋដែលបានចាក់ដូសទីពីរ នៅសាលាសង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការស្តារឡើងវិញពីជំងឺកូវីដ-១៩ តាមប្រព័ន្ធវីដេអូ សហការរៀបចំដោយសហភាពអន្តរសភា(IPU) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដោយមានការចូលរួមពីសមាជិក មកពីប្រតិភូ១៧៦ប្រទេស តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញចូលរួមពិធីប្រកាសជាផ្លូវការគណៈកម្មាធិការសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ក្រសួងមហាផ្ទៃ ហៅកាត់ថា សមាគមនារីក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋ-មន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាប្រធានសមា-គមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ តាមប្រពន្ធវីដេអូ

-បានទទួលពាក្យបណ្តឹងចំនួន៦ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៦ករណី និងកំពុងពិនិត្យសិក្សាចំនួន៦ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន២ករណី និងទទួល

លិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន២ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ចម្លងជូនគណៈកម្មការចំនួន៩ករណី។

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **សុខ យាត** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភា និងជាសមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ នៅគេហដ្ឋាននៃសព ស្ថិតក្នុងភូមិលេខ៩ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។

-សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ចុះពិនិត្យមណ្ឌលព្យាបាល និងចត្តាឡីស័កអ្នកជំងឺកូវីដ-១៩ ព្រមទាំងនាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗ ជាពិសេស ប្រជាពលរដ្ឋដែលកំពុងមានជំងឺកូវីដ-១៩ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបានបំពេញភារកិច្ចផ្សេងៗទៀត នៅមូលដ្ឋានរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន៨៧លើក។

## ២.៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភា និងគណៈប្រតិភូ បានអញ្ជើញចូលរួមក្នុងពិធីបើក និងពិធីបិទនៃមហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤២ រៀបចំដោយសភានៃប្រទេសប្រ៊ុយណេ តាមប្រព័ន្ធវីដេអូ

-ឯកឧត្តម **ឈិត គីមយាត** ប្រធានស្តីទីគណៈកម្មការទី៥ ព្រឹទ្ធសភា និងគណៈប្រតិភូ បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថវិកា និងផែនការ នៃសភាតំបន់អាស៊ី (APA) តាមប្រព័ន្ធវីដេអូ

-បានបង្កើតក្រុមមិត្តភាពព្រឹទ្ធសភាជាមួយព្រឹទ្ធសភាប៉ាគីស្ថាន និងក្រុមព្រឹទ្ធសភាទទួលបន្ទុកASEP

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មការរៀបចំកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ **(ASEP11)** ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ងួន ញ៉ិល** អនុប្រធានទី១ នៃរដ្ឋសភា ដើម្បីត្រួតពិនិត្យ

លើវឌ្ឍនភាពការងាររបស់អនុគណៈកម្មការទទួលបន្ទុកតាមផ្នែកនីមួយៗ ជាពិសេស អនុគណៈកម្មការទទួលបន្ទុកផ្នែកខ្លឹមសារ និងឯកសារ និងអនុគណៈកម្មការទទួលបន្ទុកផ្នែកព័ត៌មាន និងបច្ចេកវិទ្យាព័ត៌មាន តាមប្រព័ន្ធវីដេអូ។

ថ្ងៃសុក្រ ៤កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ឌេព ខន**

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ